ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ:...០០១/១៥.....សជណ/អពបរ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥

ថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៥ វេលាម៉ោង៨ និង ៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ**

**២- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ ស្តីពីច្បាប់អគ្គីសនី នៃព្រះរាជាណាចក្រកម្ពុជា**

**៣- សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨**

**៤- បញ្ហាផ្សេងៗ**

## ១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយមាន១០ជំពូក និង៤៦មាត្រា ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយមានគោលបំណង និងគោលដៅគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដើម្បីត្រៀមបង្ការ បន្ស៊ាំការកាត់បន្ថយគ្រោះថ្នាក់ មុនពេលមានគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិឬមនុស្ស ក៏ដូចជាការឆ្លើយតបសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ ការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ ស្តីពីច្បាប់អគ្គីសនី នៃព្រះរាជាណាចក្រកម្ពុជា

សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ ស្តីពីច្បាប់អគ្គីសនី នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវប្រកាសឲ្យ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសព្វន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៤៩០, ទូរស័ព្ទ: ០១២ ៨៤៤ ៩៧៦, ០៩៧ ៧ ៩៧០ ៦០៨
អ៊ីមែល: pressocm@gmail.com

ប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០០១ និងច្បាប់ស្តីពី វិសោធនកម្ម នៃច្បាប់ស្តីពី អត្តិសនី នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ត្រូវបានរៀបចំឡើងដោយក្រសួងរ៉ែ និងថាមពល ដើម្បីឲ្យស្របទៅតាមមាត្រាទី៥ នៃច្បាប់ស្តីពីបង្កើតក្រសួងរ៉ែ និងថាមពល ដែលត្រូវបានប្រកាសដាក់ឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១៣។

ក្រសួងរ៉ែ និងថាមពល បានរៀបចំសេចក្តីព្រាងខ្លឹមសារកែសម្រួលមាត្រាពាក់ព័ន្ធទាំងឡាយនៃច្បាប់ស្តីពី អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០១ ដើម្បីធានាការរៀបចំកែសម្រួលអាជ្ញាធរអគ្គិសនីកម្ពុជាឲ្យស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល។

**៣- សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨**

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺជាកម្មវិធីជាតិមួយដែលត្រូវបានបង្កើតឡើង និងអនុវត្តទៅតាមដំណាក់កាលៗស្រមតាមកម្មវិធីនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល។ ក្រោយការបោះឆ្នោតជាសកលឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីនយោបាយ និងឯកសារយុទ្ធសាស្ត្ររបស់ខ្លួន ដោយបានចាត់ទុកកំណែទម្រង់គ្រប់វិស័យ និងការរក្សាឲ្យបានសន្តិភាព ស្ថិរភាពនយោបាយ ជាពិសេសការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ជាការងារបន្ទាន់ និងអាទិភាពបំផុត។ តាមរយៈ ការអនុវត្តនយោបាយ «ឈ្នះ ឈ្នះ» ដែលឈរលើមូលដ្ឋាននៃស្មារតីមហាសាមគ្គីជាតិ និងឯកភាពជាតិរាជរដ្ឋាភិបាលសម្រេចបាន នូវការកសាងមូលដ្ឋានគ្រឹះនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

សមិទ្ធផលសំខាន់ៗ ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងរយៈពេលជាង២០ឆ្នាំ កន្លងមកនេះ មិនគ្រាន់តែបង្ហាញឲ្យឃើញអំពីចម្ងាយផ្លូវដែលប្រទេសកម្ពុជាបានឆ្លងកាត់នោះទេ ប៉ុន្តែក៏បានឆ្លុះបញ្ចាំងឲ្យឃើញពីការអភិវឌ្ឍរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជាដែលកើតចេញពីចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការគាំទ្រយ៉ាងពេញទំហឹង ប្រកបដោយឆន្ទៈដ៏មោះមុត ភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដ៏មានសារសំខាន់នេះ។

រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ពីការប្តេជ្ញាចិត្តយ៉ាងមោះមុត និងការផ្តល់

អាទិភាពខ្ពស់លើការបន្តកែទម្រង់រដ្ឋបាលសាធារណៈឲ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព សំដៅបម្រើប្រជាជនកាន់តែល្អប្រសើរឡើង ដោយផ្តោតលើការអនុវត្តយុទ្ធសាស្ត្រទាំងបីនៃកម្មវិធីកំណែទម្រង់រដ្ឋបាលគឺៈ

១.ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបន្តអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ និងឯកសារណែនាំស្តីពីស្តង់ដារសេវាសាធារណៈដើម្បីបង្កើនភាពឆ្លើយតបជំនឿទុកចិត្តពីអ្នកប្រើប្រាស់សេវាប្រសិទ្ធភាព និងប្រសិទ្ធផល។

២.ការអភិវឌ្ឍន៍សមត្ថភាព ការកែលំអរការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សតាមរយៈការជំរុញអនុវត្តគោលនយោបាយធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈដើម្បីលើកកម្ពស់គុណផលមន្ត្រី និងជំរុញការប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ។

៣. ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ។

ផ្អែកលើចក្ខុវិស័យខាងលើ គោលបំណងសំខាន់ៗត្រូវបានកំណត់ និងសម្រេចឲ្យបានក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ រួមមានៈ

១.សេវាសាធារណៈប្រកបដោយគុណភាពមានភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលានឹងសេចក្តីត្រូវការ មានភាពងាយស្រួល និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា។

២.ការគ្រប់គ្រង និងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ ដោយប្រកាន់ភ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិកាវិជ្ជាជីវៈ។

៣.ប្រព័ន្ធបៀវត្សដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

សកម្មភាពកែទម្រង់ ត្រូវបានរៀបចំឡើង និងដាក់ឲ្យអនុវត្តចាប់ពីឆ្នាំ ២០១៥ ដល់ ២០១៨។ ចង្កោមសកម្មភាព ត្រូវបានកំណត់ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ព្រមទាំងកែលម្អប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ។ លើសពីនេះ តារាងអនុវត្តការងារនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ បានកំណត់នូវសកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ ព្រមជាមួយសូចនាករសមិទ្ធកម្មគន្លឹះដើម្បីវាស់វែងអំពីវឌ្ឍនភាព។

គោលដៅនៃការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ គឺដើម្បីជំរុញការកែលម្អ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងសង្គមជាតិប្រកបដោយគុណភាព ប្រសិទ្ធភាព

តម្លាភាពឆ្លើយតបបានទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ឈានទៅសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ និងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## ៤- បញ្ហាផ្សេងៗ៖

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក៏បានធ្វើការផ្តាំផ្ញើរសួរសុខទុក្ខដល់កងកម្លាំងដែលឈរជើងការពារនៅតាមបណ្តោយព្រំដែន ជាពិសេសព្រំដែនកម្ពុជា-ថៃ ត្រូវខិតខំយកចិត្តទុកដាក់ការពារសុខភាព និងបន្តរក្សាទំនាក់ទំនងល្អជាមួយប្រទេសជិតខាង។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២ និង ៥៥នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥